**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

**សូមក្រាបបង្គំទូលថ្វាយ**
**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម**
**គម្រប់ ៧២ យាងចូល ៧៣ព្រះវស្សា**

***ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!***

ក្នុងឱកាសដ៏មហាមង្គលាភិរម្យថ្លៃថ្លា ក្នុងព្រះរាជពិធីបុណ្យចម្រើនព្រះជន្មគម្រប់ ៧២ យាងចូល ៧៣ព្រះវស្សា ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃពុធ ៣រោច ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២៥នេះ ទូលព្រះបង្គំជាខ្ញុំ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ នៃកងយោធពលខេមរភូមិន្ទ ក្នុងនាមទូលព្រះបង្គំនិងភរិយា សូមព្រះបរមរាជានុញ្ញាតលំឱន កាយវាចាចិត្ត ក្រាបបង្គំទូលថ្វាយនូវព្រះរាជសព្ទសាធុការពរជ័យបវរសួស្តី សិរីមង្គល វិបុលសុខ មហាប្រសើរ ថ្វាយ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** សូមទ្រង់ប្រកបដោយព្រះរាជសុខភាពល្អបរិបូរ ព្រះកាយពលរឹងមាំ ព្រះជន្មាយុយឺនយូរ។

ឆ្លៀតក្នុងឱកាសដ៏នក្ខត្តឫក្សនេះ ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា សូមព្រះបរមរាជានុញ្ញាតសម្តែងថ្វាយនូវកតញ្ញូតាធម៌យ៉ាងស្មោះស្ម័គ្របំផុត ចំពោះព្រះមហាករុណាធិគុណរបស់ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ដែលជានិច្ចកាលក្រោមព្រះបរមសិរីរាជសម្បត្តិដ៏ពិសិដ្ឋ ព្រមជាមួយព្រះរាជតម្រិះដឹកនាំប្រកបដោយព្រះបញ្ញាញាណ និងគំរូវីរភាពដ៏អង់អាចមោះមុត ពោរពេញដោយទឹកព្រះទ័យសន្តោសប្រណីយ៉ាងធំធេងដល់ប្រជានុរាស្ត្រទូទៅ តាមរយៈព្រះរាជកិច្ចសង្គមដ៏ឧត្តុង្គឧត្តម និងព្រះរាជសកម្មភាពមនុស្សធម៌នានា ក្នុងបុព្វហេតុបម្រើជាតិមាតុភូមិ និងសេចក្តីសុខក្សេមក្សាន្តរបស់ប្រជាជន។

ជាថ្មីម្តងទៀត ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា សូមលំឱនកាយវាចាចិត្ត បួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ មានទេវតារក្សាព្រះមហាស្វេតច្ឆត្រ ព្រមទាំងព្រះរាជតេជបារមី នៃអតីតព្រះមហាក្សត្រខ្មែរគ្រប់ព្រះអង្គ ប្រោស ព្រះរាជទានប្រសិទ្ធពរជ័យ មហាប្រសើរ ថ្វាយ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ប្រកបដោយព្រះរាជសុខភាពល្អបរិបូរ ព្រះកាយពលមាំមួន ព្រះជន្មាយុយឺនយូរ ដើម្បីបានគង់ប្រថាប់នៅក្នុងព្រះបរមសិរីរាជសម្បត្តិ ជាម្លប់ដ៏ត្រជាក់ត្រជុំដល់ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា ព្រមទាំងប្រជារាស្ត្រខ្មែរអស់កាលជានិច្ចនិរន្តរ៍តរៀងទៅ។

សូម **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពសក្ការៈទ្រង់ព្រះមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា។

សេចក្តីគួរពុំគួរ សូមទ្រង់ព្រះមេត្តាប្រោស។

ថ្ងៃ សុក្រ ១២កើត ខែ ពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
សូមក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី៩ ខែ ឧសភា ឆ្នាំ ២០២៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ សីហា**

វិថីហ្សកនីមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទលេខ០២៣ ៨៨៣ ២៧៤ email: generalsec@mod.gov.kh